## ព្រឹត្តិបត្របច្ចេកទេស លេខ ៧៥

# ការថែទាំ និងត្រួតពិនិត្យកូនឈើក្រោយពេលដាំ

ការថែទាំកន្លែងដាំកូនឈើឡើងវិញក្រោយពេលដាំ គឺមានសារៈសំខាន់ដើម្បីធានាអត្រារស់ខ្ពស់នៃកូនឈើដែលបានដាំ ព្រោះថាការត្រួតពិនិត្យនឹងជួយបង្ហាញនូវកត្តាជោគជ័យ និងបរាជ័យរបស់គម្រោង ។

រូបភាពទី១




## ថែរក្សាក្រោយពេលដាំ

សមាជិកសហគមន៍ព្រៃឈើទាំងអស់គួរធ្វើការរួមគ្នាដើម្បីឱ្យពួកគាត់ដឹងថាព្រំប្រទល់ និងទីតាំងព្រៃដាំកូនឈើនៅកន្លែងណា ។ នេះជាកត្តាសំខាន់ដើម្បីចៀសវាងការរុករានទន្ទ្រានកូនឈើដោយសត្វពាហនៈ (រូបភាពទី១) ។

## សកម្មភាពជួយបង្កើនអត្រារស់នៃកូនឈើ

- ពូនគល់កូនឈើជាមួយស្មៅ ចំបើង ឬ សំរាម ឬ រុក្ខជាតិស្ងួតដើម្បីជួយបង្កើនសំណើមនៅក្នុងដី (រូបភាពទី២)
- ការពារកន្លែងដាំកូនឈើពីសត្វពាហនៈ (រូបភាពទី៣)
- បង្កើតនិងថែទាំផ្លូវភ្លើង

រូបភាពទី២





រូបភាពទី៣

## ការត្រួតពិនិត្យ

មូលហេតុនៃការស្លាប់របស់កូនឈើ គឺភាគច្រើនបណ្តាលមកពី ភាពរាំងស្ងួត ទឹកជំនន់ ការយាយីដោយការលែងសត្វពាហណៈឱ្យស៊ីនិងជាន់ សត្វល្អិត និងជំងឺផ្សេងៗ (រូបភាពទី៤) ។ ដូច្នេះការត្រួតពិនិត្យនឹងជួយរកឱ្យឃើញនូវមូលហេតុទាំងនោះ ដើម្បីស្វែងរកដំណោះស្រាយសមស្របសម្រាប់កាត់បន្ថយផលប៉ះពាល់អវិជ្ជមានចំពោះកូនឈើដែលបានដាំ ។

ការត្រួតពិនិត្យក៏ជួយផងដែរក្នុងការកំណត់ភាពជោគជ័យរបស់គម្រោង (ឧ. ភាពសមស្របនៃប្រភេទកូនឈើដែលបានដាំ) និងត្រូវបង្ហាញកត្តាជោគជ័យនោះទៅដល់អ្នកចូលរួម និងសហគមន៍ទាំងមូលដឹងនិងទទួលស្គាល់ ។



រូបភាពទី៤

សន្ទស្សន៍/ចំណុចសំខាន់ៗដែលត្រូវពិនិត្យគឺ (រូបភាពី៥)

- អត្រារស់ (ចំនួនកូនឈើដែលនៅរស់/ចំនួនកូនឈើដែលបានដាំ x ១០០)
- អត្រាលូតលាស់ (កំពស់ដើមឈើគិតជាម៉ែត្រ និងគម្របកន្សោមស្លឹកគិតជាសង់ទីម៉ែត្រ)
- ប្រវែងបន្ទាត់ផ្ចិតដែលស្ថិតនៅចំណុចខ្ពស់ពីដី១.៣០ម គិតជាសង់ទីម៉ែត្រ
- ដង់ស៊ីតេស្លឹកឈើ (កាន់តែក្រាស់ កាន់តែល្អ) ។

រូបភាពទី៥




**កម្ពុជាហាវែស**
ផ្ទះលេខ ៤៦ ផ្លូវ ៣១០ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន
ក្រុងភ្នំពេញ
ទូរស័ព្ទ ០២៣ ៩៩៦ ៤១៩
harvest@fintrac.com

ព្រឹត្តិបត្រនេះរៀបចំឡើងក្រោមការឧបត្ថម្ភពីប្រជាពលរដ្ឋអាមេរិកតាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID)។

ខ្លឹមសារនៅក្នុងឯកសារនេះគឺជាការទទួលខុសត្រូវទាំងស្រុងរបស់ក្រុមហ៊ុនហ្វីនត្រាក់ Fintrac Inc. និងមិនបានឆ្លុះបញ្ចាំងពីទស្សនៈរបស់ USAID ឬរដ្ឋាភិបាលសហរដ្ឋអាមេរិកឡើយ ។